រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ១៣៧/ ១១ .រ.ប.ក អ.ជ.ប.គ.ញ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១១

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ សីហា ឆ្នាំ ២០១១
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ កញ្ញា ឆ្នាំ ២០១១

(០១/០៨/២០១១-២៥/០៨/២០១១)

អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ) បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីចូលរួមចំណែកអនុវត្ត "គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារ ដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានខិតខំអនុវត្តនៅក្នុងខែសីហា ឆ្នាំ២០១១នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ប្រចាំខែសីហាឆ្នាំ២០១១ របស់មន្ទីរប្រឆាំងគ្រឿងញៀន បានកត់សំគាល់ឃើញថា ពួកឈ្មួញគ្រឿងញៀននៅតែបន្តនាំគ្រឿងញៀនសំយោគប្រភេទមេតំហ្វេតាមីនគ្រាប់ (WY) និង មេតំហ្វេតាមីនទឹកកក (ICE) ពីតំបន់ព្រំដែននៃបណ្តាខេត្តនៅភាគឦសានចូលមកក្នុងប្រទេស ដែលតាមការកត់សំគាល់ភាគច្រើនគឺនាំឆ្លងកាត់តាមច្រករបៀង ។ ជាមួយនេះ ក្រុមជនស្បែកខ្មៅមានច្រើនសញ្ជាតិ ជាអាទិ៍ ជនជាតិសេរ៉ាឡេអូន នីហ្សេរីយ៉ា ហ្គីណេ ដែលបានចូលមកស្នាក់នៅកម្ពុជាក្រោមរូបភាពស្របច្បាប់ផ្សេងៗ បានប្រើស្ត្រីខ្មែរឱ្យទំនាក់ទំនងរកទីផ្សារលក់គ្រឿងញៀននៅក្នុងក្រុងភ្នំពេញ ។ ឯក្រុមឧក្រិដ្ឋជនកោះតៃវ៉ាន់ ក៏បានធ្វើសកម្មភាពលាក់បង្កប់គ្រឿងញៀនហេរ៉ូអ៊ីននៅក្នុងកញ្ចប់បញ្ញើអាវចម្រុះ ក្នុងទិសដៅនាំចេញពីកម្ពុជា ឆ្ពោះទៅកាន់ប្រទេសចិន ។ ដោយឡែក ការចរាចរប្រេងម្រះព្រៅភ្នំ បានកើតឡើងមួយលើក ដែលត្រូវសមត្ថកិច្ចខេត្តកំពង់ឆ្នាំងរកឃើញនិងចាប់បានក្នុងចំនួនមួយគួរកត់សំគាល់ ។

ក្រៅពីនោះ បណ្តាខេត្តមួយចំនួនទៀត ជាពិសេសនៅរាជធានីភ្នំពេញ បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ទាំងទ្រង់ទ្រាយធំ និង ទ្រង់ទ្រាយតូចៗជាច្រើនកន្លែងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការដឹកនាំ និង

ណែនាំឱ្យអនុវត្តយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ហើយផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំខាងលើ អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុវត្តសម្រេចនូវលទ្ធផលដូចខាងក្រោម :

## ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្រសួង-ស្ថាប័នជាសមាជិក ក្រសួង-ស្ថាប័នពាក់ពន្ធ័ ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានបន្តយកចិត្តទុកដាក់លើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និង គ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសកម្មភាពដូចខាងក្រោម :

### ១.១. សកម្មភាពអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីគ្រឿងញៀន

**ក. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ១ រូប ចូលរួមក្នុងកិច្ចប្រជុំជំហានដំបូង ស្តីពីការប្រឡងប្រណាំងរមណីយដ្ឋានស្អាត និងការងាររៀបចំពង្រឹងសហគមន៍ទេសចរណ៍ នៅសណ្ឋាគារសាន់វ៉េ ថ្ងៃទី១៦/៨/២០១១ ដែលមានអ្នកចូលរួម **២២៤** នាក់ ។ នៅក្នុងកិច្ចប្រជុំនេះ ក៏មានប្រារព្ធពិធីប្រគល់-ទទួល ខិត្តបណ្ណ័ផ្សព្វផ្សាយអប់រំពីគ្រឿងញៀន អេដស៍ ការជួញដូរមនុស្ស និង ការជួញដូរអាវុធជាតិផ្ទុះ ដល់រាជធានី-ខេត្តទាំង ២៤ សរុបមានចំនួន **៦.000** សន្លឹក (មានពប្រភេទទំហំ ដែលបោះពុម្ពដោយក្រសួងទេសចរណ៍ ជាភាសាខ្មែរ មានចំនួន ៣.000 សន្លឹក និងភាសាបរទេស មានចំនួន ៣.000 សន្លឹក) ។

**ខ. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកំពង់ចាម** បានចាត់តំណាង (ស្នងការដ្ឋាននគរបាល)ចូលរួមផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍CTN ក្រោមប្រធានបទស្តីពីការទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកំពង់ចាម ក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១) ។

### ១.២. សកម្មភាពបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យផ្សព្វផ្សាយអប់រំ

**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ** បានចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប ទៅចូលរួមក្នុងការដាក់ពិន្ទុលើការលើកកម្ពស់សីលធមិសង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលរៀបចំដោយគណៈកម្មាធិការជាតិលើកកម្ពស់សីលធមិសង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សហការជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា កាលពីថ្ងៃទី ២៩/៧/២០១១ ដើម្បីបណ្តុះគំនិតយុវវ័យឱ្យចេះស្រឡាញ់ និងយល់ដឹងពីសារៈសំខាន់នៃវប្បធមិ សីលធមិសង្គម និងតម្លៃស្ត្រី រួមទាំងចំណេះដឹងអំពី **គ្រឿងញៀន** ។ កម្មវិធីនេះ មានការចូលរួមពីនិស្សិតនៃ សាកលវិទ្យាល័យ **មេគង្គកម្ពុជា**, សាកលវិទ្យាល័យ **បៀលប្រាយ** និងសាកលវិទ្យាល័យ **បញ្ញាសាស្ត្រ** សរុបចំនួន ៧៥ នាក់ ។

សកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់ជាប្រចាំរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ, ក្រសួង-ស្ថាប័ន, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ចំនួន ៨ (ដូចមានរាយឈ្មោះនៅក្នុងតារាងឧបសម្ពន្ធ) និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន មានអ្នកចូលរួមសរុប **២.៧៥៣** នាក់ និងការបណ្តុះបណ្តាលចំណេះដឹងពីវប្បធមិ សីលធមិសង្គម តម្លៃស្ត្រី និងការយល់ដឹងពីគ្រឿងញៀន ដល់ក្រុមនិស្សិតចំនួន ៣ សកលវិទ្យាល័យ មានអ្នកចូលរួម **៧៥** នាក់ (សរុប **២.៨២៨** នាក់) ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

ខែសីហាឆ្នាំ២០១១នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម ៖

### ២.១. ការបង្ក្រាបបទល្មើសគ្រឿងញៀន

**-បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៦៦** ករណី ប្រៀបធៀប ខែកក្កដា ឆ្នាំ២០១១ (បទល្មើស **៦២** ករណី) គឺកើន ឡើង **៦,៤៥** % ។

**-ឃាត់ខ្លួនជនសង្ស័យ** ចំនួន **១៤៨** នាក់ ប្រៀបធៀប ខែកក្កដា ឆ្នាំ២០១១ (ឃាត់ខ្លួនជនសង្ស័យ **១៤៨** នាក់) គឺស្មើគ្នា ។ គ្រប់ករណី និង ជនសង្ស័យទាំងអស់ខាងលើ បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង ដើម្បីអនុវត្តតាមផ្លូវច្បាប់ ។

**-វត្ថុតាងចាប់យក** រួមមាន មេតំហ្វេតាមីនគ្រាប់ WY ៥.៧១៣ គ្រាប់, មេតំហ្វេតាមីនក្រាមម្សៅ(Ice) ២.៣៧៩,៩៣ ក្រាម, អ៊ិចស្តាស៊ី ២ គ្រាប់, ហេរ៉ូអ៊ីន ៣៥០,៥៦ ក្រាម, ដើមកញ្ឆា ១៩៥ ដើម, កញ្ឆាក្រៀម ៩ គ.ក្រ និង ៤៥,៦ ក្រាម, ប្រេងម្រះព្រៅភ្នំ ចំនួន ៣ ហ្វុយ(មានចំណុះពេញ) និង ១ហ្វុយ(មានចំណុះស្មើរកន្លះហ្វុយ) [(១)] (សរុប ៦០០ លីត្រ និង ១២៣ គីឡូក្រាម) រួមទាំងវត្ថុតាងរួមផ្សំមួយចំនួនទៀត ដូចមានរាយនៅក្នុងតារាងឧបសម្ព័ន្ធ ។

### ២.២. ការធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង

**មន្ទីរពិសោធន៍គ្រឿងញៀន** របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងក្នុងខែសីហានេះ បានចំនួន ១៥១ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀន** មាន **០៩ សំណាក = ០៦ %** និងសំណាក **វិជ្ជមានសារធាតុញៀន ១៤២ សំណាក** រួមមាន មេតំហ្វេតាមីនក្រាមម្សៅ (Ice) ៦៤ សំណាក = ៤២ %, មេតំហ្វេតាមីនគ្រាប់ WY៥៩ សំណាក = ៣៩ %, កញ្ឆាក្រៀម ០១ សំណាក = ១ %, ជ័រកញ្ឆា ០២ សំណាក = ១ %, កេតាមីន ១១ សំណាក = ៧%, ហេរ៉ូអ៊ីន ០៣ សំណាក = ២ %, កូកាអ៊ីន ០១ សំណាក = ១ %, MDMA ០១ សំណាក = ១ % ។

### ២.៣. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ

ដោយឡែក សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយ ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) នៅក្នុងខែសីហាឆ្នាំ២០១១នេះ សរុបមានចំនួន ***៣.៧២២.១៥៥*** គីឡូក្រាម (មានរាយមុខសារធាតុគីមីលំអិតនៅក្នុងតារាងឧបសម្ព័ន្ធ) ។

## ៣. ការព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

ខែសីហាឆ្នាំ២០១១នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ជាសមា-

---

(១) ប្រេង ៣ ហ្វុយ ដែលមានចំណុះពេញ ស្មើនឹង ៦០០ លីត្រ និង ១ ហ្វុយ ដែលមានចំណុះស្មើរកន្លះហ្វុយ (ថ្លឹងហើយឃើញមានចំនួន ១២៣ គីឡូក្រាម)

ជិក រួមទាំងអង្គការជាតិ អន្តរជាតិ ដើម្បីបន្តយកចិត្តទុកដាក់លើការងារព្យាបាល មានដូចតទៅ ៖

### ៣.១. *ការងារព្យាបាល ស្តារនីតិសម្បទា*

➢ **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ**

- បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងកម្មវិធីប្រចាំថ្ងៃ របស់មណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី១៩/៨/២០១១ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ក្នុងគោលបំណងធ្វើឱ្យកម្មវិធីនេះ ក្លាយជាកម្មវិធីផ្លូវការនិងអនុវត្តបានឯកភាពគ្នា( មានអ្នកចូលរួម១៩នាក់) ។
- បានសហការជាមួយក្រសួងសុខាភិបាល ក្នុងការដំឡើងបញ្ជីឈ្មោះ មន្ទីរពេទ្យ និង មណ្ឌលសុខភាព ដែលត្រូវដាក់ឱ្យដំណើរការសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ សម្រាប់ឆ្នាំដំបូង (២០១១) សរុបមាន ១២២ កន្លែង ក្នុងនោះ មន្ទីរពេទ្យបង្អែក មាន ៥៤ កន្លែង និង មណ្ឌលសុខភាព មាន ៦៨ កន្លែង ។
- បានប្រជុំពិភាក្សាលើការរៀបចំដោះស្រាយសុខភាព ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន ដែលកំពុងនៅតាមពន្ធនាគារទូទាំងប្រទេស ។
- បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ FM102 នៃមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ក្រោមប្រធានបទ "ការព្យាបាលដោយមេតាដូន" (២៣/៨/២០១១) ។

➢ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ)** បានម្ចាស់ការរៀបចំថវិកាសម្រាប់ឆ្នាំ២០១២ ដើម្បីផ្តល់ឱ្យមណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅទូទាំងប្រទេស ។

### ៣.២. *ការកាត់បន្ថយគ្រោះថ្នាក់*

➢ ***នៅក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ៖*

- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមប្រជុំពិភាក្សាលើផែនការប្រតិបត្តិ និងកម្មវិធីគាំទ្ររួមចំពោះមេរោគអេដស៍/ជំងឺអេដស៍ សម្រាប់ ឆ្នាំ២០១១-២០១៥ (HIV/AIDS Joint Support Program Operational Plan and Budget 2011-2015) ដែលបានព្រាងដោយប្រពន្ធ័ក្រុមអង្គការសហប្រជាជាតិ (UN Team)នៅកម្ពុជា(១១/៨/២០១១) ។
- បានសហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រះសីហនុ ក្រោមការគាំទ្រដោយគម្រោងមូលនិធិសកលជុំទី៧ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន/អេដស៍ នៅថ្ងៃទី២១-២២/៧/២០១១ ដល់មន្ត្រីពាក់ពន្ធ័នៅក្នុងក្រុងព្រះសីហនុ (មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, មន្ទីរទេសចរណ៍, មន្ទីរកិច្ចការនារី, មន្ទីរការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ, នគរបាល, អាវុធហត្ថ, លេខាធិការដ្ឋានគ្រឿងញៀនខេត្ត) សរុបចំនួន ២៨ នាក់ និងបើកវគ្គបណ្តុះបណ្តាលដូចគ្នានេះ ក្រោមការគាំទ្រដោយគម្រោងមូលនិធិសកលជុំទី៧ ដដែល នៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី៣០-៣១/៨/២០១១ មានសមាសភាពដូចខាងលើ ចូលរួម ចំនួន ២៨ នាក់ (សរុបរួម **៥៦** នាក់) ។

- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ១ រូប ទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការឆ្លើយតបដៃគូសហគមន៍ដើម្បីប្រជាជនប្រឈមមុខខ្ពស់កាលពីថ្ងៃទី០៤-០៥/៨/២០១១ នៅសណ្ឋាគារខ្សាច់មាសខេត្តព្រះសីហនុ ។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ លេខាធិការដ្ឋានអេដស៍ខេត្ត មន្ទីរសុខាភិបាលរាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តបាត់ដំបង ស្នងការនគរបាលខេត្តព្រះសីហនុ ភ្នំពេញ អង្គការ FHI, KHANA, RHAC, UNAID, UNICEF, DFO, PSI, KHEMARA, PSF, CVD, KWCD, MHC, WHC, WNU និងក្រុមបុរសស្រឡាញ់បុរស សរុប **៥០**នាក់ ។

➢ ***នៅក្រៅប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ និងមន្ត្រីរបស់អគ្គលេខាធិការដ្ឋាន ២ រូប ទៅចូលរួមកិច្ចប្រជុំស្តីពីការធ្វើអង្កេតសង្គមសាស្ត្រ (Social Reserch) កាលពីថ្ងៃទី០៨-១២/៨/២០១១ នៅទីក្រុងបាងកក ប្រទេសថៃ តាមការអញ្ជើញរបស់កម្ម វិធី HAARP ប្រចាំនៅទីក្រុងបាងកក ប្រទេសថៃ ។ ដើម្បីអនុវត្តនូវទ្រឹស្តីនៃការអនុវត្តន៍ការធ្វើអង្កេតសង្គមសាស្ត្រ កម្ពុជាបានជ្រើសរើសប្រធានបទមួយគឺ ទស្សនៈរបស់សហគមន៍ចំពោះអ្នកប្រើគ្រឿងញៀន ហើយតាមរយៈប្រធានបទ និងសំណួរ ដែលបានលើកឡើងដោយសិក្ខាកាមកម្ពុជាគឺត្រឹមត្រូវនិងសមស្របតាមការណែនាំ ហើយស្របទៅតាមសភាពការណ៍ជាក់ស្តែងនៅកម្ពុជា ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក៏ដូចជាបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ប្រទេសក្នុងអនុតំបន់ តំបន់ និងបណ្តាអង្គការជាដៃគូជាតិ អន្តរជាតិ ដើម្បីលើកកម្ពស់សមត្ថភាពការងារអនុវត្តច្បាប់ តាមរយៈសកម្មភាពដូចតទៅ :

### ៤.១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ និងមន្ត្រីស្រួងពាក់ពន្ធ័ សហការជាមួយអង្គការ UNODC ចុះទៅធ្វើការអង្កេតដើម្បីបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ (BLO) នៅខេត្តកំពត (១៧-១៩/៨/២០១១) ។
- បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីបញ្ហាគ្រឿងញៀន និងឧក្រិដ្ឋកម្មឆ្លងដែន នៅថ្ងៃទី២៤-២៦/៨/២០១១ នៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ ក្រោមគម្រោងស្តីពីភាពជាដៃគូនៃមន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (PATROL) របស់អង្គការ UNODC ។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីមន្ត្រីអនុវត្តច្បាប់ថ្នាក់កណ្តាល និងមន្ត្រីការិយាល័យ BLO សំខាន់ៗចំនួន ៧ គឺ ការិយាល័យ BLO ភ្នំដិន ត្រពាំងផ្លុង ប៉ោយប៉ែត ចាំយាម បាវិត ជ្រៃធំ ក្អមសំណ សរុបទាំងអស់ **៤៣** រូប ។
- បានសម្របសម្រួលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និងខេត្តរតនគីរី ដើម្បីចាត់វិធានការអនុវត្តតាមចំណុចដែលបានឯកភាពគ្នា នៅក្នុងកំណត់ហេតុទ្វេភាគី កម្ពុជា-ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខានៅថ្ងៃទី ២៦/៧/២០១១ នៅខេត្តចំប៉ាសាក់ (ឡាវ) រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជា

មួយគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀនឡាវ ។

- អគ្គលេខាធិការ បានដឹកនាំកិច្ចប្រជុំពិភាក្សាដើម្បីដោះស្រាយបញ្ហាអ្នកញៀនគ្រឿងញៀន ដែលកំពុងជាប់នៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារនៅទូទាំងប្រទេស ។

### ៤.២. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តព្រំដែន

- ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ នៅអធិការដ្ឋានស្រុកកំពង់ស្រឡៅ មានបើកកិច្ចប្រជុំថ្នាក់ក្រុមការងារ នៃអធិការដ្ឋាននគរបាលស្រុកកំពង់ស្រឡៅ ស្រុកឆែប និង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (សរុប១២នាក់) ជាមួយស្នងការដ្ឋាននគរបាលស្រុកមឿងខូង ខេត្តចំប៉ាសាក់ ប្រទេសឡាវ (សរុប១៣នាក់) ដើម្បីផ្លាស់ប្តូរសភាពការណ៍ និងពង្រឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន កម្ពុជា-ឡាវ ។
- ថ្ងៃទី 0៤ ខែ សីហា ឆ្នាំ ២០១១ នៅស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ មានបើកកិច្ចប្រជុំថ្នាក់ស្នងការ រវាងស្នងការនគរបាលខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ដោយមានការចូលរួមពីថ្នាក់ដឹកនាំមន្ទីរប្រឆាំងគ្រឿងញៀន (សរុបចំនួន ៣៩ នាក់)ជាមួយថ្នាក់ដឹកនាំស្នងការដ្ឋាននគរបាលខេត្តចំប៉ាសាក់ (សរុប ២0 នាក់) ដើម្បីពិនិត្យ និងសម្រេចលើលទ្ធផល នៃកិច្ចប្រជុំរបស់ក្រុមការងារ កាលពីថ្ងៃទី ២២ខែកក្កដា ឆ្នាំ២០១១(ខាងលើ) ពាក់ពន្ធ័នឹងកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែន កម្ពុជា-ឡាវ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើនកិច្ចសហប្រតិបត្តិការ ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ក៏ដូចជាបណ្តាអង្គការជាដៃគូអភិវឌ្ឍន៍នានា ដូចមានសកម្មភាពខាងក្រោម :

➢ ***នៅក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន :*

- បានរៀបចំលិខិតផ្លូវការ ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ទៅគណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀន អេដស៍ និងពេស្យាចារ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ពន្ធ័នៃរដ្ឋាភិបាលវៀតណាម ដើម្បីគាំទ្រដល់សំណើរបស់កម្ពុជា ពាក់ពន្ធ័នឹងការជួយកសាងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- អគ្គលេខាធិការ បានជួបពិភាក្សាការងារជាមួយប្រតិភូ នៃស្ថាប័នរដ្ឋបាលអនុវត្តច្បាប់ប្រឆាំងគ្រឿងញៀន សហរដ្ឋអាមេរិក (Drug Enforcement Administration. DEA) ។ នៅក្នុងជំនួបពិភាក្សាការងារជាមួយ ស្ថាប័ន DEA អគ្គលេខាធិការដ្ឋាន បានស្នើសុំឱ្យភាគី DEA បន្តជួយដល់កម្ពុជា ក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិ-បត្តិការទ្វេភាគីលើការងារត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា, ការចែករំលែកនូវបទពិសោធន៍ និងការផ្តល់ព័ត៌មានទៅវិញទៅមកឱ្យកាន់តែល្អ ដើម្បីឱ្យការងារបង្ក្រាបបទល្មើសគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព, ការបន្តជួយពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ការផ្តល់នូវសម្ភារៈ មធ្យោបាយសម្រាប់អង្គភាពប្រតិបត្តិការ ព្រមទាំងជួយមន្ទីរពិសោធន៍គ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទាំងការពង្រឹងសមត្ថភាពមន្ត្រី និងការផ្តល់នូវឧបករណ៍សម្ភារៈនានា ។

➢ ***នៅក្រៅប្រទេស*** គណៈប្រតិភូជាន់ខ្ពស់ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ចំនួន ៩ រូប ដឹកនាំដោយ ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអញ្ជើញទៅទស្សនកិច្ចនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីថ្ងៃទី២៥-២៨/៧/ ២០១១ ។

ដោយឡែក អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានចាត់មន្ត្រីមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន ចំនួន ២ រូប ទៅចូលរួមសិក្ខាសាលាស្តីពីកម្មវិធី Global SMART ប្រចាំតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ នៅក្រុងបាងកក ប្រទេសថៃ (១៨-២០/៧/២០១១) ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវកម្មវិធី Global SMART លើការចែករំលែកព័ត៌មានស្តីពីគ្រឿងញៀន ពិសេសគ្រឿងញៀនប្រភេទ ATS និងវិធានការឆ្លើយតបរបស់សាមីប្រទេសនីមួយៗ ព្រមទាំងការពិភាក្សាលើជំហានអនុវត្តបន្តក្នុងកម្មវិធីនេះប្រចាំតំបន់នៅពេលអនាគត ។

ក្រៅពីការអនុវត្តន៍ទិសដៅសកម្មភាពពហុវិស័យខាងលើ ដោយមានកិច្ចសហការពីវិទ្យាស្ថានស្ថិតិនៃក្រសួងផែនការ ក្រុមការងារទិន្នន័យរបស់អគ្គលេខាធិការដ្ឋាន បានខិតខំអនុវត្តសម្រេចលទ្ធផលដូចខាងក្រោម :

**១.** បានបញ្ចប់ការសរសេរកម្មវិធីគ្រប់គ្រងទិន្នន័យព័ត៌មានគ្រឿងញៀន តាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដែលក្នុងនោះ ៖

១.ក. បានសរសេរចប់ទាំងស្រុងនូវកម្មវិធីគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ (តាមការសាកល្បងបញ្ចូលទិន្នន័យរបស់ខេត្តបន្ទាយមានជ័យ ប្រព័ន្ធនេះអាចដំណើរការបានគ្របដណ្តប់ទាំង ២៤ រាជធានី-ខេត្ត) ។

១.ខ. បានសរសេរចប់សៀវភៅណែនាំការប្រើប្រាស់កម្មវិធីគ្រប់គ្រងទិន្នន័យ ស្របតាមទំរង់នៃសម្រង់ទិន្នន័យ ។

**២.** មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន បានទទួលកម្មវិធីគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងគ្រឿងញៀន/អេដស៍ សម្រាប់គ្រប់គ្រងទិន្ន័យអ្នកប្រើគ្រឿងញៀន ដែលបានទៅទទួលសេវាព្យាបាលនៅក្នុងមន្ទីរពេទ្យ និងមណ្ឌលបណ្តោះអាសន្ន ។

**៣.** បានបង្កើតតារាងសម្រាប់កត់ត្រា សំណុំរឿងបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅតុលាការ ។

**៤.** ក្រុមការងារប៉ាន់ប្រមាណពីចំនួនអ្នកប្រើគ្រឿងញៀននៅកម្ពុជា ដោយមានកិច្ចសហការពីអង្គការខាន់ណា បាននិងកំពុងបន្តសកម្មភាពរបស់ខ្លួន ។ បច្ចុប្បន្នការសិក្សានេះមានឈ្មោះថា **ការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា និងឥរិយាបថគ្រោះថ្នាក់របស់ពួកគេ** ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ក្នុងខែសីហាឆ្នាំ២០១១នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដោយមានការចូលរួមពីក្រសួង-ស្ថាប័នជាសមាជិក ក៏ដូចជាក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ព្រមទាំងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការជាតិ-អន្តរជាតិ ដែលពាក់ព័ន្ធនានា បានអនុវត្តតាមទិសដៅសកម្មភាពពហុវិស័យទាំង៥ ដែលបានដាក់ចេញកាលពីខែកក្កដា កន្លងទៅទទួលបានលទ្ធផលល្អប្រសើរ ។ ប៉ុន្តែយើងក៏បានកត់សំគាល់ឃើញមាន **បញ្ហាប្រឈម** និង **ចំណុចខ្វះខាត** មួយចំនួនផងដែរ ។ លើការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីគ្រឿងញៀន គឺយើងមិនសូវមានឱកាសបានធ្វើការអប់រំដោយផ្ទាល់ និងឱ្យបានស៊ីជម្រៅទៅដល់ក្រុមគោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ។ ចំណែកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន តាម

រយៈការអនុវត្តន៍នូវ "គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព" ធ្វើឱ្យបទល្មើសគ្រឿងញៀន មានការថយចុះបើប្រៀបធៀបនឹងត្រីមាសទី១កន្លងទៅ ប៉ុន្តែចំណុចខ្វះខាតជារួម ការផលិតកែច្នៃគុណភាពជាទ្រង់ទ្រាយតូចៗនៅតែបន្តកើតមានដោយដុំ ដោយកន្លែងនៅឡើយ ។ ដោយឡែក ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន យើងក៏កំពុងតែមានបញ្ហាប្រឈមនឹងចំនួនកើនឡើងនៃអ្នកញៀនគ្រឿងញៀនដែលសមត្ថកិច្ចបានបញ្ជូនមក បន្ទាប់ពីការអនុវត្តន៍ "គោលនយោបាយភូមិឃុំមាន សុវត្ថិភាព" របស់រាជរដ្ឋាភិបាល ។ ជាមួយនេះ ការអនុវត្តន៍កម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ ក៏នៅមិនទាន់មានដំណើរការបានពេញលេញ ដើម្បីអាចជួយដោះបន្ទុកដល់មណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋដែលមានបច្ចុប្បន្ននេះនៅឡើយ ។

## IV. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែកញ្ញា ឆ្នាំ២០១១

ដើម្បីឈានទៅសម្រេចទិសដៅសកម្មភាពពហុវិស័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. អគ្គលេខាធិការដ្ឋាន នឹងបន្តសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត (អាចខេត្តបន្ទាយមានជ័យ ឬ ខេត្តស្ទឹងត្រែង) ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CTN ក្រោមប្រធានបទស្តីពី សកម្មភាព និង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

១.២. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងជាសមាជិក របស់ អ.ជ.ប.គ.ញ និងអង្គការជាតិ-អន្តរជាតិ តាមរយៈសកម្មភាពនានា ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រោះថ្នាក់នៃគ្រឿងញៀន និងការលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ដើម្បីចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើហិង្សា ។

១.៣. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយគម្រោងមូលនិធិសកលជុំទី៧ ដើម្បីរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពីការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន/អេដស៍ នៅតាមបណ្តាខេត្តគោលដៅមួយចំនួនទៀត ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

៣.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសម្របសម្រួលជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត (ជាពិសេសខេត្តនៅតាមព្រំដែន) ដើម្បីពង្រឹងលើការងារត្រួតពិនិត្យបទល្មើសគ្រឿងញៀន និងសារធាតុគីមីផ្សំ ទាំងនៅតាមបណ្តាច្រកព្រំដែនអន្តរជាតិ ច្រកទ្វេភាគី និងច្រករបៀង ព្រមទាំងបន្តជំរុញកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន នៅក្នុងប្រទេស ទាំងករណីធំៗ និងករណីតូចតាច ។

៣.២. អគ្គលេខាធិការដ្ឋាន នឹងសហការជាមួយអង្គការUNODC បន្តធ្វើការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែនសមុទ្រ (BLO) នៅខេត្តកំពត ។

៣.៣. អគ្គលេខាធិការដ្ឋាន នឹងបន្តសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលទិន្នន័យ

ស្តីពីការ នាំចូល នាំចេញ និងប្រើប្រាស់សារធាតុគីមីផ្សំ ។

៣.៤. អគ្គលេខាធិការដ្ឋាន ត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាពីលទ្ធផលបឋមពាក់ពន្ធ័ដំណើរការសិក្សា និងប្រមូលព័ត៌មាន លើការងារត្រួតពិនិត្យនិងគ្រប់គ្រងសារធាតុគីមីផ្សំនៅខេត្តស្វាយរៀង និង ខេត្តកណ្តាល ។

## ៣. ការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

៣.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីតាមដានសំណើសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានដាក់ស្នើសុំទៅភាគីវៀតណាម តាមរយៈកិច្ចប្រជុំគណៈកម្មការចម្រុះទ្វេភាគីកម្ពុជា-វៀតណាម លើកទី១២ ។

៣.២. អគ្គលេខាធិការដ្ឋាន នឹងសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល មណ្ឌលបណ្តោះអាសន្នអប់រំបន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៣.៣. អគ្គលេខាធិការដ្ឋាន នឹងបន្តធ្វើការសម្របសម្រួលជាមួយក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យពិនិត្យគ្រឿងញៀនរាជធានី-ខេត្តពាក់ព័ន្ធ ដើម្បីបង្កើនល្បឿននៃការរៀបចំការអនុវត្តន៍នូវការផ្តល់សេវាព្យាបាលតាមសហគមន៍ លើគោលដៅ ២០% នៃឃុំ-សង្កាត់គោលដៅ ។

៣.៤. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការអនុវត្តន៍កម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន ដោយប្រើប្រាស់ឱសថមេតាដូន ។

## ៤. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់

៤.១. អគ្គលេខាធិការដ្ឋាន នឹងបន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ និងក្រសួងពាក់ពន្ធ័នានា គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តនៅតាមព្រំដែន កម្ពុជា-ឡាវ ដើម្បីបន្តការរៀបចំក្រុមការងារចម្រុះចុះជួយលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៤.២. អគ្គលេខាធិការដ្ឋាន នឹងសហការសម្របសម្រួលជាមួយអង្គការដៃគូអភិវឌ្ឍ គណៈកម្មាធិការត្រួតពិនិត្យខេត្ត ដែលមិនទាន់បានបណ្តុះបណ្តាល ដើម្បីបន្តបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពីការអនុវត្តន៍ច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ ។

៤.៣. អគ្គលេខាធិការដ្ឋាន នឹងតាមដានបន្តនូវសេចក្តីព្រាងច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានបញ្ជូនទៅរដ្ឋសភា ។

៤.៤. អគ្គលេខាធិការដ្ឋាន នឹងសហការសម្របសម្រួលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ និង ខេត្តរតនគីរី ដើម្បីអនុវត្តតាមស្មារតីនៃកំណត់ហេតុប្រជុំទ្វេភាគី កម្ពុជា-ឡាវ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនដែលបានចុះហត្ថលេខានៅថ្ងៃទី២៦/៧/២០១១ នៅខេត្តចំប៉ាសាក់ ( ប្រទេសឡាវ) ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. អគ្គលេខាធិការដ្ឋាន នឹងត្រៀមលក្ខណៈជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អញ្ជើញទៅទស្សនកិច្ចនៅសហព័ន្ធរុស្ស៊ី ។

៥.២. អគ្គលេខាធិការដ្ឋាន នឹងចាត់បញ្ជូនប្រតិភូទៅចូលរួមកិច្ចប្រជុំទ្វេភាគី កម្ពុជា- ចិន លើកទី២ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅប្រទេសចិន (០៥-០៩/៩/២០១១) ។

៥.៣. អគ្គលេខាធិការដ្ឋាន នឹងត្រៀមចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប ទៅចូលរួមសិក្ខាសាលាស្តីពីការស៊ើបអង្កេតមន្ទីរពិសោធន៍ផលិតគ្រឿងញៀនលួចលាក់ នៅសហរដ្ឋអាមេរិក (០៧-១០/៩/២០១១) ។

៥.៤. អគ្គលេខាធិការដ្ឋាន នឹងបន្តតាមដានការស្នើសុំបញ្ចូលគម្រោងស្នើសុំហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណង សម្រាប់គម្រោងស្តីពី "ការពង្រឹងសមត្ថភាពស្ថាប័នសម្របសម្រួលកិច្ចការត្រួតពិនិត្យ គ្រឿងញៀនថ្នាក់ជាតិ" ដែលបានដាក់ស្នើទៅរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ។

៥.៥. អគ្គលេខាធិការដ្ឋាន នឹងត្រៀមរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងបញ្ហាគ្រឿងញៀន និងត្រៀមចូលរួមប្រជុំត្រៀមសម្រាប់កិច្ចប្រជុំ "ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន" (ក.ស.វ.អ) នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាថ្ងៃទី ០៥/៩/២០១១ ។

ក្រៅពីអនុវត្តទិសដៅសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាន នឹងបន្តអនុវត្តការងារមួយចំនួនទៀតដូចជា :

- បន្តជំរុញការរៀបចំផែនការជាតិ ៥ ឆ្នាំ (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- ត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ដល់មន្ត្រីលេខាធិការដ្ឋានគ្រឿងញៀន/អេដស៍រាជធានី-ខេត្ត ក្នុងការប្រើប្រាស់ប្រព័ន្ធកម្មវិធីបញ្ចូលទិន្នន័យ តាមផែនការប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀនដើម្បីមន្ត្រីលេខាធិការដ្ឋានអាចបញ្ចូលទិន្នន័យទៅក្នុងកម្មវិធីដោយខ្លួនឯងង ។
- ត្រៀមបោះពុម្ពសៀវភៅណែនាំការប្រើប្រាស់កម្មវិធីគ្រប់គ្រងទិន្នន័យ ដើម្បីចែកជូនលេខាធិការដ្ឋានគ្រឿងញៀន/អេដស៍រាជធានី-ខេត្ត ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អជបគញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អជបគញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

## សកម្មភាពសំខាន់ៗក្នុងការដឹកនាំ
## អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ខែសីហា ឆ្នាំ២០១១

| ល.រ | ខ្លឹមសារ និង គោលដៅ |
|---|---|
| ១ | បានណែនាំឲ្យរៀបចំប្រជុំ ពិភាក្សាលើសេចក្តីព្រាងកម្មវិធីប្រចាំថ្ងៃរបស់មណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ថ្ងៃទី១៩ សីហា ២០១១ |
| ២ | បានណែនាំឲ្យរៀបចំបញ្ជីឈ្មោះ មន្ទីរពេទ្យ និង មណ្ឌលសុខភាព ដែលត្រូវផ្តល់សេវាព្យាបាលដោយផ្អែកលើសហគមន៍ សម្រាប់ឆ្នាំ២០១១ និងសម្រាប់ ៥ ឆ្នាំទៅមុខ នូវមន្ទីរពេទ្យ និង មណ្ឌលសុខភាព ដែលត្រូវផ្តល់សេវាព្យាបាលដោយផ្អែកលើសហគមន៍នៅទូទាំងប្រទេស |
| ៣ | បានណែនាំឲ្យមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន បន្តកិច្ចសហការក្នុងការរៀបចំចងក្រងទិន្នន័យព័ត៌មានគ្រឿងញៀន ដោយប្រើប្រាស់ប្រពន្ធ័កុំព្យូទ័ ឲ្យបានកាន់តែសមស្របតាមលក្ខណៈបច្ចេកវិទ្យាព័ត៌មាន |
| ៤ | បានណែនាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំថវិកាបេឧបត្ថម្ភជនរងគ្រោះដោយសារគ្រឿងញៀនស្នាក់នៅក្នុងមណ្ឌល ដើម្បីបញ្ចូលទៅក្នុងផែនការថវិកាឆ្នាំ២០១២ |

## សកម្មភាពផ្សព្វផ្សាយអប់រំ ប្រចាំខែ សីហា ឆ្នាំ២០១១

| ល.រ | ឈ្មោះស្ថាប័ន | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ | -បានចូលរួមប្រជុំបូកសរុបជំហានដំបូងស្តីពី ការប្រឡងប្រណាំងមេណីយដ្ឋានស្អាត និងការរៀបចំពង្រឹងសហគមន៍ទេសចរណ៍ សណ្ឋាគារសោភ័ះ ១៦.៨.២០១១ (**២២៤** នាក់)<br>-បានចូលរួមក្នុងពិធីប្រគល់ទទួល Sticker ផ្សព្វផ្សាយអប់រំពីគ្រឿងញៀន អេដស៍ ជួញដូរមនុស្ស និងជួញដូរអាវុធជាតិផ្ទុះ ដែលផលិតដោយក្រសួងទេសចរណ៍ ចំនួន ៦.០០០ សន្លឹក<br>-បានចូលរួមដាក់ពិន្ទុដល់និស្សិតសកលវិទ្យាល័យមេគង្គកម្ពុជា សកលវិទ្យាល័យបៀលប្រាយ សកលវិទ្យាល័យបញ្ញាសាស្ត្រ ចំនួន **៧៥** នាក់ ពីការលើកកម្ពស់ការយល់ដឹងអំពីសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ នៅអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា | ២៩៩ នាក់ |
| ២ | កំពង់ចាម | -ផ្តល់បទសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន ស្តីពី ការទទួលខុសត្រូវរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ក្នុងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន<br>-លេខាធិការដ្ឋានគ្រឿងញៀនខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងពិធីផ្សព្វផ្សាយការចាត់តាំងអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព(**២៤១** នាក់/ស្រី៤៤) | ២៤១ នាក់ |
| ៣ | ប៉ៃលិន | -លេខាធិការដ្ឋានគ្រឿងញៀនខេត្តប៉ៃលិន សហការជាមួយ CHED ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន (**៨៩** នាក់) | ៨៩ នាក់ |
| ៤ | បាត់ដំបង | -នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោកឃ្មុំ ស្រុកថ្មគោល បានបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍ ក្នុងកម្មវិធីផ្សព្វផ្សាយការអនុវត្តន៍ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ (**៣១២** នាក់ / ស្រី ១២២ នាក់) | ៣១២ នាក់ |
| ៥ | កំពង់ធំ | -ស្រុកបារាយណ៍ សហការជាមួយស៊ី.ស៊ី.ដេប ចុះផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ៤លើក/៤ឃុំ ( **២០០** នាក់/ស្រី ៥៨ នាក់)<br>-មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់សិក្ខាកាមកសិកម្ម ស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល្ល័ង្គ (**១៦០** នាក់/ស្រី ៨៩ នាក់) | ៣៦០ នាក់ |
| ៦ | ក្រចេះ | -នគរបាលប៉ុស្តិ៍រដ្ឋបាល នៃស្រុកព្រែកប្រសព្វ ចុះផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន (**២៧១** នាក់/ស្រី ១២១ នាក់)<br>-អាជ្ញាធរស្រុកស្នួល សហការជាមួយអង្គការលើកាដូ បានបញ្ជ្រាបការងារអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន នៅក្នុងឱកាសនៃការផ្សព្វផ្សាយអំពើហឹង្សាក្នុងគ្រួសារ និងអំពើជួញដូរកេទ(**៧៧** នាក់/ស្រី ២៣នាក់) | ៣៤៨ នាក់ |
| ៧ | តាកែវ | -នគរបាលប៉ុស្តិ៍រដ្ឋបាល នៃស្រុកទ្រាំង ចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (**៤៤៦** នាក់/ស្រី ២៣២ នាក់)<br>-អាជ្ញាធរស្រុក បុរីជលសារ, កោះអណ្តែត, ទ្រាំង, បានចុះធ្វើការអប់រំផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន ៤ លើក/៤ឃុំ (**២២២** នាក់/ស្រី៨៥ នាក់) | ៦៦៨ នាក់ |
| ៨ | រតនគិរី | -នគរបាលប្រឆាំងគ្រឿងញៀនខេត្ត បានចុះផ្សព្វផ្សាយអំពីច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅសកលវិទ្យា | ៣៧៣ នាក់ |

| | | | |
|---|---|---|---|
| | | *ល័យ បៀលប្រាយ សាខាខេត្ត (**៣៧៣** នាក់/ស្រី ២៥ នាក់)* | |
| *៩* | *ឧត្តរមានជ័យ* | *-អធិការដ្ឋាននគរបាលស្រុកអន្លង់វែង បានចុះផ្សព្វផ្សាយពីច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគ្រោះថ្នាក់នៃគ្រឿងញៀន (**៦៣** នាក់/ស្រី៣៥ នាក់)* | *៦៣ នាក់* |
| | | *សរុប* | ***២.៧៥៣ នាក់*** |

## *បទល្មើសគ្រឿងញៀនដែលបង្ក្រាប ក្នុងខែ សីហា ឆ្នាំ២០១១*

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ដឹកជញ្ជូន ជួញដូរ | | | ផលិត | | | ដាំដុះ ចម្រាញ់ប្រេងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | **9** | **23** | **2** | 9 | 23 | 2 | | | | | | | | | | | | |
| 2 | ន.ប ភ្នំពេញ | **18** | **52** | **6** | 15 | 43 | 6 | | | | | | | 3 | 8 | 0 | 0 | 1 | 0 |
| 3 | ន.ប កណ្តាល | **1** | **4** | **0** | 1 | 4 | 0 | | | | | | | | | | | | |
| 4 | ន.ប កំពង់ឆ្នាំង | **2** | **1** | **0** | 1 | 0 | 0 | | | | 1 | 1 | 0 | | | | | | |
| 5 | ន.ប កំពង់ចាម | **7** | **12** | **1** | 4 | 4 | 0 | | | | | | | 3 | 8 | 1 | | | |
| 6 | ន.ប ព្រះសីហនុ | **2** | **3** | **2** | 2 | 3 | 2 | | | | | | | | | | | | |
| 7 | ន.ប ព្រៃវែង | **2** | **6** | **0** | 2 | 6 | 0 | | | | | | | | | | | | |
| 8 | ន.ប ស្វាយរៀង | **1** | **2** | **0** | 1 | 2 | 0 | | | | | | | | | | | | |
| 9 | ន.ប ស្ទឹងត្រែង | **2** | **3** | **2** | 2 | 3 | 2 | | | | | | | | | | | | |
| 10 | ន.ប ព្រះវិហារ | **1** | **2** | **1** | 1 | 2 | 1 | | | | | | | | | | | | |
| 11 | ន.ប បាត់ដំបង | **6** | **12** | **2** | 6 | 12 | 2 | | | | | | | | | | | | |
| 12 | ន.ប បន្ទាយមានជ័យ | **11** | **20** | **3** | 9 | 15 | 3 | | | | | | | 2 | 5 | 0 | | | |
| 13 | ន.ប ពោធិ៍សាត់ | **1** | **2** | **0** | | | | | | | | | | 1 | 2 | 0 | | | |
| 14 | ន.ប មណ្ឌលគិរី | **2** | **3** | **1** | 1 | 2 | 1 | | | | | | | 1 | 1 | 0 | | | |
| 15 | ន.ប ប៉ៃលិន | **1** | **3** | **1** | 1 | 2 | 1 | | | | | | | | | | 0 | 1 | 0 |
| | **សរុប** | **66** | **148** | **21** | **55** | 121 | 20 | | | | **1** | 1 | 0 | **10** | 24 | 1 | **0** | 2 | 0 |

## *វត្ថុតាងចាប់យក ប្រចាំខែ សីហា ឆ្នាំ២០១១(រាយតាមអង្គភាពប្រតិបត្តិការ)*

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | **WY** (គ្រាប់) | **ICE** (ក្រាម) | **Heroine** (ក្រាម) | ដើមកញ្ញា ម២ | កញ្ញាក្រៀម (ក្រាម) | **Ecstasy** (គ្រាប់) | **Pseudo-Ephedrine** | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
| *1* | មន្ទីរប្រឆាំងគ្រឿងញៀន | *4.425* | *2350,36* | *347,8* | | | *2* | | | |
| *2* | ន.ប ភ្នំពេញ | *28* | *9,43* | *2,76* | | | | | | |
| *3* | ន.ប កំពង់ឆ្នាំង | | | | *195* ដើម | | | | | *113,4 Kg* និង*3*ហ្វូយ |
| *4* | ន.ប កំពង់ចាម | | *0,11* | | | | | | | |
| *5* | ន.ប ព្រះសីហនុ | | *9,99* | | | | | | | |
| *6* | ន.ប ព្រៃវែង | | *0,06* | | | *9Kg45g* | | | | |
| *7* | ន.ប ស្វាយរៀង | | *6,80* | | | *0,6* | | | | |
| *8* | ន.ប ស្ទឹងត្រែង | *213* | | | | | | | | |
| *9* | ន.ប ព្រះវិហារ | *2* | | | | | | | | |
| *10* | ន.ប បាត់ដំបង | *38* | *0,63* | | | | | | | |
| *11* | ន.ប បន្ទាយមានជ័យ | *823* | *2,31* | | | | | | | |
| *12* | ន.ប មណ្ឌលគិរី | *180* | *0,24* | | | | | | | |
| *13* | ន.ប ប៉ៃលិន | *3* | | | | | | | | |
| | សរុប | ***5.713*** | ***2.379,93*** | ***350,56*** | ***195*** ដើម | ***9****Kg* ***45,6*** *g* | ***2*** | | | ***123*** *Kg* និង ***600 L*** |

**វត្ថុតាងផ្សេងៗ៖**

-មន្ទីរប្រឆាំង គ្រ.ញ — WY ២,៣ ក្រាម, Heroin ១ កញ្ចប់តូច, ជញ្ជីង៣, រថយន្ត១, ម៉ូតូ៦, លុយ ២២៤.៦០០ រៀល, ៣.០០០ គីម, ៤ដុល្លារ, ២.០០០ ដុង, សម្ភារៈប្រើប្រាស់មួយចំនួន

| | |
|---|---|
| -ន.ប ភ្នំពេញ | ជញ្ជីង៣, អាវុធខ្លី៣ដើម, ម៉ូតូ ១០, លុយ ២៤០.៩០០ រៀល, ២០០ ដុល្លារ, ១០ រីងហ្គីត, លុយឥណ្ឌូនេស៊ី ១០.០០០ សម្ភារៈប្រើប្រាស់មួយចំនួន |
| -ន.ប កណ្ដាល | ម៉ូតូ ១, សម្ភារៈប្រើប្រាស់មួយចំនួន |
| -ន.ប កំពង់ឆ្នាំង | រថយន្ត១ |
| -ន.ប ព្រះសីហនុ | កញ្ឆាក្រៀម ៣ កញ្ចប់តូច, កាំភ្លើងខ្លី ១, លុយ ២.៤៣៩ ដុល្លារ, ២.៧៧៣.៤០០ រៀល, សម្ភារៈប្រើប្រាស់មួយចំនួន |
| -ន.ប ព្រៃវែង | ម៉ូតូ ២ |
| -ន.ប ស្វាយរៀង | ជញ្ជីង១, លុយ ១.០០០.០០០ ដុង, ៥០ ដុល្លារ |
| -ន.ប បាត់ដំបង | WY កន្លះគ្រាប់, ដាវ ៤, រថយន្ត ១, លុយ ២៥២.០០០ រៀល |
| -ន.ប បន្ទាយមានជ័យ | WY កន្លះគ្រាប់ និង ២,១ក្រាម, |
| -ន.ប ពោធិ៍សាត់ | សម្ភារៈប្រើប្រាស់មួយចំនួន |
| -ន.ប មណ្ឌលគីរី | លុយ ៣០២.១០០ រៀល, ១០ ដុល្លារ, |